CFA®

*Khmer*

# សុវត្ថិភាពអគ្គីភ័យក្នុង គេហដ្ឋានរបស់លោកអ្នក



# 1 មូលហេតុទូទៅនៃអគ្គីភ័យក្នុងគេហដ្ឋាន



ចង្ក្រានគឺជាប្រភពគ្រោះថ្នាក់អគ្គីភ័យដ៏ចំបងមួយ



ឆែកមើលកុងតាក់ភ្លើងថានៅដំណើរការល្អ

អង្គភាពពន្លត់អគ្គីភ័យចូលរួមពន្លត់អគ្គីភ័យតាមគេហដ្ឋានចំនួនជាង 1000 ដង រៀងរាល់ឆ្នាំ។

អគ្គីភ័យដែលបណ្ដាលឲ្យបាត់បង់ជីវិតភាគច្រើនកើតឡើងនៅក្នុងគេហដ្ឋាន ក៏ប៉ុន្តែសោកនាដកម្មពិតនោះគឺថា ភាគច្រើននៃអគ្គីភ័យទាំងនេះគឺអាចជៀងវាងបាន។

ការធ្វេសប្រហែសតែមួយភ្លែតនៅក្នុងចង្ក្រានបាយ ឧបករណ៍ប្រើអគ្គីសនីដែលខូច ឬខោអាវបោកគក់ដាក់នៅជិតម៉ាស៊ីនកំដៅពេក ទាំងអស់នេះអាចនាំឲ្យមានបច្ច័យគ្រោះថ្នាក់បណ្ដាលឲ្យខូចខាតសំណង់គេហដ្ឋានសំខាន់ៗ ឬអាចបណ្ដាលឲ្យសមាជិកគ្រួសារមានគ្រោះថ្នាក់។

ជាសំណាងល្អ មានកិច្ចការសាមញ្ញមួយចំនួនដែលលោកអ្នកអាចធ្វើបានដើម្បីការពារគ្រួសាររបស់លោកអ្នកពីគ្រោះថ្នាក់អគ្គីភ័យ។ ចំណាយពេលដើម្បីឆែកចំណុចសំខាន់ៗរបស់លោកអ្នក ហើយត្រូវធានាថាលោកអ្នកមានឧបករណ៍ប្រកាសអាសន្នផ្សេងដែលដំណើរការ ហើយការរៀបចំផែនការភៀសខ្លួនពីគេហដ្ឋានអាចផ្ដល់ជូនលោកអ្នកនូវឱកាសប្រសើរជាងក្នុងការជៀសវាងពីឥទ្ធិពលបំផ្លិចបំផ្លាញរបស់អគ្គីភ័យ។

## អគ្គីភ័យក្នុងគេហដ្ឋានភាគច្រើនបំផុតគឺចាប់ផ្ដើមនៅក្នុងផ្ទះបាយ

- ផ្ទះបាយគឺជាប្រភពគ្រោះថ្នាក់អគ្គីភ័យដ៏ចំបងមួយ។
- មិនត្រូវដើរចោលអាហារដែលកំពុងចំអិនទេ។
- សំអាតខ្លាញ់និងកំណាកខ្លាញ់ឲ្យបានស្អាតនៅលើចង្ក្រាននិងកន្លែងអាំងសាច់។
- ដាក់កន្សែងជូតដៃនិងវាំងននឲ្យឆ្ងាយពីចង្ក្រាននិងប្រដាប់អាំងនំប៉័ង។
- ពាក់អាវដែលមានដៃរឹបនៅពេលចំអិនម្ហូបអាហារ។

## ខ្សែភ្លើងខូចគឺមានគ្រោះថ្នាក់

- ត្រូវប្រាកដថាកុងតាក់ភ្លើងទាំងអស់គឺនៅដំណើការល្អ។ ខ្សែភ្លើងមិនត្រូវនៅលាតទេ ហើយជានិច្ចជាកាលត្រូវស្រោបឲ្យជិត។
- ការជួសជុលទាំងអស់ត្រូវធ្វើដោយជាងអគ្គីសនីដែលមានចុះឈ្មោះត្រឹមត្រូវ។ កុំព្យាយាមជួសជុលដោយខ្លួនឯង។
- កុំប្រើចំណុចដោតឌុយអគ្គីសនីលើសចំណុះ។ ការប្រើអាដាប់ទ័រនិងបន្ទះរន្ធដោតឌុយ ច្រើនអាចធ្វើឲ្យចំណុចដោតឌុយអគ្គីសនីប្រើលើសចំណុះ។
- កុំដាក់ខ្សែភ្លើងសំរាប់បន្តនៅខាងក្រោមព្រំឬគ្រឿងសង្ហារឹម។
- តម្លើងកុងតាក់សុវត្ថិភាព។ កុងតាក់នេះនឹងផ្ដាច់អគ្គីសនីភ្លាមៗពីបន្ទះចែកចាយអគ្គីសនី ប្រសិនបើឃើញមានគំហុកអគ្គីសនីភ្លាមៗ។ សំរាប់ព័ត៌មានបន្ថែម សូមបើកមើលគេហទំព័ររបស់ សុវត្ថិភាពថាមពលរដ្ឋវិចតូរីយ៉ា នៅ **www.esv.vic.gov.au**

# 1 មូលហេតុទូទៅនៃអគ្គីភ័យក្នុងគេហដ្ឋាន



ដាក់របាំងនៅពីមុខឡកំដៅចំហរ



សំអាតតំរងម៉ាស៊ីនសម្ងួតខោអាវ

## ឧបករណ៍ប្រើអគ្គីសនី

- ត្រូវធ្វើឲ្យបានប្រាកដថាសំភារៈទាំងនោះប្រើតាមការណែនាំរបស់ក្រុមហ៊ុនផលិត។
- ឆែកមើលសំភារៈប្រើអគ្គីសនីថានៅដំណើរការល្អ។ ត្រូវជួសជុលនិងពិនិត្យមើលដោយជាងអគ្គីសនីដែលមានចុះឈ្មោះត្រឹមត្រូវ ប្រសិនបើលោកអ្នកមានការបារម្មណ៍ ជាពិសេសគឺសំភារៈដែលគេប្រើហើយ។
- ប្តូរឌុយនិងខ្សែភ្លើងដែលខូចដោយជាងអគ្គីសនីដែលមានចុះឈ្មោះត្រឹមត្រូវ។
- បិទឧបករណ៍ប្រើអគ្គីសនីទាំងនោះនៅចំណុចកុងតាក់នៅពេលឈប់ប្រើ។
- ប្រសិនបើមានអគ្គីភ័យ បិទភ្លើងភ្លាមៗនៅចំណុចកុងតាក់ ឬបន្ទះចែកចាយអគ្គីសនី ប្រសិនបើមានសុវត្ថិភាពធ្វើដូចនេះបាន។

## ភួយអគ្គីសនី

- មិនត្រូវបើកភ្លើងភួយអគ្គីសនីពេញមួយយប់ ឬនៅក្នុងពេលថ្ងៃទេ - បើកវាប្រហែល 30នាទីមុននឹងចូលសំរាន្ត។
- ទុកដាក់ភួយអគ្គីសនីទៅតាមការណែនាំរបស់ក្រុមហ៊ុនផលិត។
- កុំដាក់វត្ថុធ្ងន់នៅលើភួយអគ្គីសនីដែលកំពុងមានចរន្តអគ្គីសនី។ នេះរួមបញ្ចូលទាំងសត្វចិញ្ចឹមផងដែរ។
- កុំសំរាន្តដោយដណ្តប់ភួយអគ្គីសនីពីលើ។

## ការជក់បារីលើគ្រែ

- មិនត្រូវជក់បារីលើគ្រែជាដាច់ខាត។
- រងើកភ្លើងអាចធ្លាក់លើកំរាលពូកហើយឆេះបន្តិចម្តងៗរួចបណ្តាលឲ្យឆេះជាអណ្តាតភ្លើងនៅពេលលោកអ្នកសំរាន្តលក់។
- ត្រូវប្រាកដថាពន្លត់កន្ទុយបារីមុននឹងបោះចោល។

## ម៉ាស៊ីនសម្ងួតខោអាវ

- សំអាតតំរងកំទេចកំទីក្រោយពេលប្រើប្រាស់ម្តងៗ។
- ទុកឲ្យម៉ាស៊ីនបញ្ចប់វដ្តត្រជាក់។

## ម៉ាស៊ីនកំដៅក្នុងគេហដ្ឋាន

- បិទម៉ាស៊ីនកំដៅនៅពេលចូលសំរាន្ត។
- កុំដាក់ខោអាវនៅជិតម៉ាស៊ីនកំដៅពេក។
- ត្រូវធានាថាម៉ាស៊ីនកំដៅនិងបំពង់ខ្យល់តម្លើងនិងថែទាំដោយអ្នកវិជ្ជាជីវៈ។
- ឆែកមើលតាមជញ្ជាំងនិងកំរាលដើរថាមានរុំទ្រនាប់ត្រឹមត្រូវពីប្រភពកំដៅ ហើយម៉ាស៊ីនកំដៅត្រូវដាក់ឲ្យបានឆ្ងាយពីសំភារៈដែលអាចឆេះបាន។
- ត្រូវប្រយ័ត្នប្រយែងពីកន្លែងដាក់ម៉ាស៊ីនកំដៅដែលអាចលើកចុះឡើងបាន។
- ដាក់រនាំងបាំងមុខឡកំដៅចំហរ។
- មិនត្រូវទុកឲ្យភ្លើងនៅឆេះជាដាច់ខាតក្រោយពីលោកអ្នកចូលសំរាន្តឬចាកចេញពីគេហដ្ឋាន។ ត្រូវប្រាកដថាផេះត្រជាក់ហើយមុននឹងចាក់ចោល។
- មិនត្រូវទុកកូនក្មេងចោលនៅក្បែរឡកំដៅចំហរឬម៉ាស៊ីនកំដៅឡើយ។

## ទៀននិងប្រដាប់ដុតប្រេង

- ទុកទៀនឲ្យបានឆ្ងាយពីវាំងនននឹងសំភារៈដែលអាចឆាបឆេះបានដទៃទៀត។
- ជានិច្ចជាកាលត្រូវប្រើលើផ្ទៃដែលមិនងាយឆេះ។
- ត្រូវប្រាកដថាលោកអ្នកប្រើទឹកនិងប្រេងនៅក្នុងចានគោម។



សំអាតតំរងម៉ាស៊ីនសម្ងួតខោអាវ

# 2

# បង្រៀនកូនក្មេងឲ្យចេះប្រយ័ត្នប្រយែង ពេលនៅក្បែរភ្លើង




ទុកឈើគូសឲ្យផុតពីដៃកូនក្មេង



បង្រៀនកូនក្មេងឲ្យចេះឲ្យឈើគូសមកមនុស្សពេញវ័យ

- គ្រោះថ្នាក់មួយក្នុងបួនក្នុងចំណោមកូនក្មេងទាក់ទងនឹងការរលាកភ្លើង។
- ទុកឈើគូស ដែកកេះ និងទៀនទាំងអស់ឲ្យផុតពីដៃកូនក្មេងតូចៗ។
- ប្រើប្រាស់ដែកកេះដែលមានសុវត្ថិភាពសំរាប់កូនក្មេង។
- បង្រៀនកូនៗរបស់លោកអ្នកឲ្យចេះឲ្យឈើគូសនិងដែកកេះទាំងអស់មកមនុស្សពេញវ័យ។
- ត្រូវប្រាកដថាកូនក្មេងដែលមានអាយុច្រើនជាងដឹងថាឈើគូសអាចប្រើបានតែនៅពេលមានវត្តមានរបស់មនុស្សពេញវ័យប៉ុណ្ណោះ។
- បង្រៀនកូនក្មេងឲ្យចេះទូរស័ព្ទមកលេខ 000 នៅពេលមានអាសន្ន។
- អប់រំកូនៗរបស់លោកអ្នក ដូច្នេះពួកគេដឹងរបៀបចេញពីគេហដ្ឋាននៅក្នុងករណីមានអគ្គីភ័យ។
- ធ្វើការហ្វឹកហាត់ពេលមានអគ្គីភ័យឲ្យបានទៀងទាត់ជាមួយកូនក្មេង ដូច្នេះពួកគេដឹងកន្លែងសំរាប់ជួបជុំគ្នានៅពេលទៅដល់ខាងក្រៅគេហដ្ឋាន។
- ណែនាំកូនក្មេងឲ្យចេះអោន ហើយចេញ ចេញ ចេញ នៅពេលដែលមានផ្សែងនៅក្នុងគេហដ្ឋាន។ *
- បង្រៀនកូនក្មេងឲ្យឈប់ ផ្តល់ខ្លួនហើយរមាលខ្លួន ប្រសិនបើខោអាវពួកគេឆេះភ្លើង*



សាកល្បងផ្លូវគៀសខ្លួនពេលមានអគ្គីភ័យ

* សូមមើលក្បួនសំរាប់រស់រានជីវិតពីអគ្គីភ័យ - ទំព័រទី 10

# 3 ឧបករណ៍ប្រកាសភាពអាសន្ន ផ្សែងដែលដំណើរការ គឺជួយជីវិត

## គ្រួសារជាច្រើនជំពាក់ជីវិតរបស់ខ្លួននឹង ឧបករណ៍ប្រកាសអាសន្នផ្សែងដែល ដំណើរការ

លោកអ្នកមិនអាចហិតក្លិនផ្សែងបានទេនៅពេលសំរាន្តលក់ ដូច្នេះហើយឧបករណ៍ប្រកាសអាសន្នផ្សែងគឺជាប្រព័ន្ធប្រកាសអាសន្នពីដំបូងដ៏សំខាន់ ដើម្បីប្រាប់លោកអ្នកនិងគ្រួសារឲ្យដឹងជាមុនពីគ្រោះថ្នាក់នៃផ្សែងនិងអគ្គិភ័យ។

បទបញ្ញត្តិសំរាប់អាគារចែងថា នៅគ្រប់គេហដ្ឋានក្នុងរដ្ឋវិចតូរីយ៉ាត្រូវតែមានឧបករណ៍ប្រកាសអាសន្នផ្សែងដែលផលិតតាមស្តង់ដាអូស្ត្រាលី AS 3786។ គេហដ្ឋាននាពេលបច្ចុប្បន្នអាចមានតម្លើងឧបករណ៍ប្រកាសអាសន្នផ្សែងប្រើថ្មពិល ក៏ប៉ុន្តែគេហដ្ឋានសាងសង់ថ្មីទាំងអស់ត្រូវមានបំពាក់ឧបករណ៍ប្រកាសអាសន្នផ្សែងដែលមានភ្ជាប់ខ្សែរួចជាស្រេចមុននឹងការចូលនៅ។ ឧបករណ៍ប្រកាសអាសន្នដែលមានភ្ជាប់ខ្សែរួចជាស្រេចក៏នៅត្រូវការថ្មពិលសំរាប់ផ្តល់ជាថាមពលជំនួយ។

ទោះបីជាមានបទបញ្ញត្តិក៏ដោយ ការស្រាវជ្រាវបង្ហាញថា តាមការចូលរួមរបស់ផ្នែកសេវាកម្មអគ្គិភ័យ មានតែ 45 ភាគរយនៃគេហដ្ឋានប៉ុណ្ណោះដែលមានឧបករណ៍ប្រកាសអាសន្នផ្សែង ហើយក្នុងចំណោមនេះ 31 ភាគរយ មិនមានដំណើរការទេ។

លោកអ្នកអាចធានាថាជានិច្ចជាកាល ឧបករណ៍ប្រកាសអាសន្នផ្សែងរបស់លោកអ្នក ការពារគ្រួសាររបស់លោកអ្នក ដោយរក្សាវាឲ្យដំណើរការបានល្អ។

- តេស្តមើលជារៀងរាល់សប្តាហ៍ដោយចុចប៊ូតុង តេស្តជាមួយនឹងដងអំបោស ដើម្បីប្រាកដថាឧបករណ៍នោះចេញសំឡេងរោទិ៍។
- សំអាតធូលីលើឧបករណ៍ប្រកាសអាសន្នផ្សែងជាមួយអំបោសរបស់ម៉ាស៊ីនបូមធូលី។
- ប្តូរថ្មពិលយ៉ាងហោចណាស់មួយឆ្នាំម្តង។ ជាការងាយស្រួលដើម្បីចងចាំ ប្រសិនបើលោកអ្នកប្តូរថ្មនៅពេលលោកអ្នកប្តូរម៉ោងនាឡិកាតាមការសន្សំពន្លឺថ្ងៃ។

ឧបករណ៍ប្រកាសអាសន្នផ្សែងដែលមិនដំណើរការ គឺមិនមានប្រយោជន៍អ្វីទេ ហើយវាផ្តល់នូវអារម្មណ៍មិនពិតថាមានសន្តិសុខ។

## ធ្វើជម្រើសឲ្យបានត្រឹមត្រូវ

ឧបករណ៍ប្រកាសអាសន្នផ្សែងមិនជាថ្លៃទេ ហើយងាយស្រួលនឹងតម្លើង។ នៅពេល ជ្រើសរើសឧបករណ៍ប្រកាសអាសន្នសំរាប់គេហដ្ឋានរបស់លោកអ្នក ត្រូវប្រាកដថា ជ្រើសរើសឧបករណ៍ដែលសមស្របតាមស្តង់ដាអូស្ត្រាលី AS 3786 ។

ឧបករណ៍ប្រកាសអាសន្នផ្សែងមានពីរប្រភេទ – ឧបករណ៍ប្រកាសអាសន្នអ៊ីយ៉ូដដែលនឹងចាប់ រកយ៉ាងលឿនសលប់នូវវត្ថុមាននៃបំណែកតូចបំផុតនៃផ្សែង ហើយនឹងប្រភេទឧបករណ៍ប្រកាសអាសន្នថ្មីជាង ជាអ៊ីឡិចត្រូនិចរូបថតសំរាប់តាមរកផ្សែងដែលអាចមើលឃើញ។

ការស្រាវជ្រាវបង្ហាញថា ទោះបីជាឧបករណ៍ប្រកាសអាសន្នទាំងពីរប្រភេទនេះផ្តល់ឱកាសដល់អ្នករស់នៅក្នុងគេហដ្ឋានដើម្បីភៀសខ្លួន ឧបករណ៍ប្រកាសអាសន្នផ្សែងប្រភេទអ៊ីឡិចត្រូនិចរូបថត តែងតែមានប្រសិទ្ធភាពជាងក្នុងការតាមរកអគ្គិភ័យដែលឆេះបន្តិចម្តងៗនៅក្នុងគេហដ្ឋាន។

- អង្គភាពពន្លត់អគ្គិភ័យទទូចឲ្យអ្នករស់នៅក្នុងគេហដ្ឋានទាំងអស់បន្ថែមឧបករណ៍ប្រកាសអាសន្នផ្សែងប្រភេទអ៊ីឡិចត្រូនិចរូបថត លើឧបករណ៍ប្រកាសអាសន្នផ្សែងអ៊ីយ៉ូដរបស់ខ្លួន។

## ការតម្លើងឲ្យបានត្រឹមត្រូវគឺសំខាន់ណាស់

សំរាប់ការការពារអប្បបរិមា តម្លើងឧបករណ៍ប្រកាសអាសន្នផ្សែងនៅខាងក្រៅបន្ទប់គេងនិមួយៗ ឬផ្នែកសំរាប់គេងនៅក្នុងគេហដ្ឋានរបស់លោកអ្នក។ ប្រសិនបើលោកអ្នករស់នៅក្នុងគេហដ្ឋានដែលមានលើសពីមួយជាន់ តម្លើងឧបករណ៍ប្រកាសអាសន្នផ្សែងតាមជាន់និមួយៗ។

ជាការប្រសើរ បើសិនជាអាចភ្ជាប់ឧបករណ៍ប្រកាសអាសន្នផ្សែងទៅវិញទៅមក។ ប្រភេទនៃឧបករណ៍ប្រកាសអាសន្នផ្សែងខ្លះអាចភ្ជាប់ជាមួយគ្នាទៅវិញទៅមកបាន ដូចនេះនៅពេលដែលឧបករណ៍ប្រកាសអាសន្នមួយបញ្ចេញសំឡេងរោទិ៍ ឧបករណ៍ប្រកាសអាសន្នដ៏ទៃទៀតក៏បញ្ចេញសំឡេងរោទិ៍ដែរ។

គេហដ្ឋានដែលមានផ្នែកម្ខាងសំរាប់កូនក្មេង គួរតែមានឧបករណ៍ប្រកាសអាសន្នភ្ជាប់ជាមួយឧបករណ៍ប្រកាសអាសន្ននៅក្បែរបន្ទប់មនុស្សពេញវ័យ។ ការសិក្សាបានបង្ហាញថា កូនក្មេងដែលគេងលក់ចំនួន 85 ភាគរយ មិនភ្ញាក់ដោយសារសំឡេងរោទិ៍នៃឧបករណ៍ប្រកាសអាសន្នផ្សែងទេ។

**ឌីយ៉ាក្រាមទី 1:** ឧបករណ៍ប្រកាសអាសន្នផ្សែងនៅតាមគេហដ្ឋាន




**ឌីយ៉ាក្រាមទី 2:** អគារស្នាក់នៅដែលមានបរិវេណសំរាប់គេងដាក់ដោយឡែក




**ឌីយ៉ាក្រាមទី 3:** ទីកន្លែងគ្មានខ្យល់និងការតម្លើងឧបករណ៍ប្រកាសអាសន្នផ្សែងត្រឹមត្រូវលើជញ្ជាំងខាង។




ចំងាយពីចំណុចចុងបំផុតនៃជំរាលពិដានទៅដល់តម្រូវឧបករណ៍ប្រកាសអាសន្នផ្សែងត្រូវមានចំងាយពី 500mm ទៅ 1500mm។



តេស្តឧបករណ៍ប្រកាសអាសន្នផ្សែង រៀងរាល់សប្តាហ៍



សំអាតធូលីលើឧបករណ៍ប្រកាសអាសន្នផ្សែងជាមួយម៉ាស៊ីនបូមធូលី

ម្ចាស់ផ្ទះមានការទទួលខុសត្រូវក្នុងការធានាថាឧបករណ៍ប្រកាសអាសន្នត្រូវបានតម្លើងនៅតាមគេហដ្ឋានសំរាប់ជួល។ អនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិត នៅពេលតម្លើងឧបករណ៍ប្រកាសអាសន្នផ្សែង។

- នៅលើពិដាន: ឧបករណ៍ប្រកាសអាសន្នផ្សែងគួរដាក់នៅចំកណ្តាលពិដាន។ បើមិនអាចដាក់នៅចំកណ្តាលបាន ត្រូវដាក់ចំងាយ 300mm ពីជ្រុងឬជញ្ជាំងណាមួយ។
- នៅលើជញ្ជាំង: ឧបករណ៍ប្រកាសអាសន្នផ្សែងគួរដាក់នៅចំងាយ 300mm ទៅ 500mm ពីពិដាន។
- នៅលើពិដានជំរាលឬចោត: ឧបករណ៍ប្រកាសអាសន្នផ្សែងគួរដាក់នៅចំងាយ 500mm ទៅ 1500mm ពីចំណុចដែលខ្ពស់ជាងគេ។
- ជៀសវាងខ្យល់ត្រជាក់: កុំតម្លើងឧបករណ៍ប្រកាសអាសន្នផ្សែងនៅជិតបង្អួច ទ្វារ ឬបំពង់ខ្យល់ ដែលជាកន្លែងអាចមានខ្យល់ត្រជាក់ដែលអាចប៉ះពាល់ដល់ការដឹងរបស់ឧបករណ៍ប្រកាសអាសន្ន។
- ជៀសវាងទីកន្លែងគ្មានខ្យល់: ទីកន្លែងគ្មានខ្យល់គឺជាកន្លែងដែលខ្យល់ក្តៅនៅនឹងមួយកន្លែង បណ្តាលឲ្យផ្សែងមិនអាចមកដល់ឧបករណ៍ប្រកាសអាសន្នបាន។ ជាទូទៅ ទីកន្លែងនេះគឺនៅខាងចុងបំផុតនៃពិដានចោតឬជំរាល ជ្រុងជញ្ជាំងនិងពិដាន និងនៅចន្លោះធ្នឹមកំរាលក្តារដែលមើលឃើញ។

សំរាប់ព័ត៌មានបន្ថែមអំពីការតម្លើងឧបករណ៍ប្រកាសអាសន្នផ្សែងត្រឹមត្រូវ សូមបើកមើលវិបសាយ:
**www.buildingcommission.com.au**

## ឧបករណ៍ប្រកាសអាសន្នផ្សែងសំរាប់មនុស្សអន់ថយខាងស្តាប់សំឡេង

មានឧបករណ៍ប្រកាសអាសន្នផ្សែងសំរាប់មនុស្សអន់ថយខាងស្តាប់សំឡេង។ ឧបករណ៍នេះ អាចមានអំពូលភ្លើងភ្លឹបភ្លែត និង/ឬ មានបន្ទះញ័រដែលអាចដាក់នៅក្រោមខ្នើយ ហើយបន្ទះនេះនឹងចាប់ផ្តើមញ័រនៅពេលដែលឧបករណ៍ប្រកាសអាសន្នបញ្ចេញសំឡេងរោទិ៍។

ឧបករណ៍ប្រកាសអាសន្នខ្លះត្រូវបានគេរចនាបថសំរាប់តភ្ជាប់ជាមួយឧបករណ៍ប្រកាសអាសន្នផ្សែងបំពងសំឡេងធម្មតានៅតាមទីកន្លែងផ្សេងៗគ្នាក្នុងគេហដ្ឋាន។ ប្រសិនបើឧបករណ៍ប្រកាសអាសន្នណាមួយតាមរកឃើញផ្សែង ឧបករណ៍ទាំងអស់នឹងបញ្ចេញសំឡេងរោទិ៍ អំពូលភ្លើងនឹងភ្លឹភ្លឹបភ្លែត ហើយបន្ទះញ័រនឹងចាប់ផ្តើមដើរ។

ឧបករណ៍ប្រកាសអាសន្នដទៃទៀតគឺអាចលើកចុះឡើងបានដែលអាចយកពីគេហដ្ឋានមួយទៅគេហដ្ឋានមួយទៀតបាន។

មិនមានស្តង់ដាអូស្ត្រាលីសំរាប់ឧបករណ៍ប្រកាសអាសន្នសំរាប់មនុស្សពិការភ្នែក ថ្លង់និង អន់ថយខាងស្តាប់សំឡេងទេ ក៏ប៉ុន្តែគឺមានស្តង់ដាសំរាប់ផ្នែកខ្លះនៃឧបករណ៍សំរាប់តាមរកផ្សែងនិងប្រកាសអាសន្នតែប៉ុណ្ណោះ។ អង្គភាពពន្លត់អគ្គីភ័យណែនាំឲ្យប្រជាជនទិញឧបករណ៍ប្រកាសអាសន្នដែលមានស្រង់ស្តង់ដា AS 3786។

សំរាប់ព័ត៌មានបន្ថែមសំរាប់ការអន់ថយនៃការស្តាប់សំឡេង អាចរកមើលបាននូវ:

**សង្គមសំរាប់មនុស្សថ្លង់វិចតូរីយ៉ា**
**www.vicdeaf.com.au**
**ព័ត៌មានលើអ៊ីនធើណិតពីពិការភាព**
**www.disability.vic.gov.au**

## ការប្តូរនិងបោះចោលឧបករណ៍ប្រកាសអាសន្នផ្សែង

ឧបករណ៍ប្រកាសអាសន្នផ្សែងមិនចេះតែដំណើរការជារៀងរហូតនោះទេ ហើយជាទូទៅ មានការកំណត់ពេលវេលាសំរាប់រយៈពេលប្រហែល 10ឆ្នាំ។ ប្រសិនបើឧបករណ៍ប្រកាសអាសន្នផ្សែងរបស់លោកអ្នកមានអាយុចាស់ជាងនេះ អង្គភាពពន្លត់អគ្គីភ័យស្នើសុំលោកអ្នកប្តូរចេញ។

ឧបករណ៍ប្រកាសអាសន្នផ្សែងខ្លះមានកាលបរិច្ឆេទនៃការប្រើប្រាស់បោះពុម្ពនៅលើតែម្តង ក៏ប៉ុន្តែបើឧបករណ៍ប្រកាសអាសន្នរបស់លោកអ្នកនៅតែបញ្ចេញសំឡេងរោទិ៍បន្ទាប់ពីដូរថ្មពីលរួចមក លោកអ្នកគួរតែប្តូរថ្មី។

ចាប់តាំងពីខែកញ្ញា ឆ្នាំ2007 តទៅ ច្បាប់អនុញ្ញាតឲ្យបោះចោលឧបករណ៍ប្រកាសអាសន្នផ្សែងជាមួយនឹងសំរាមតាមគេហដ្ឋាន។

# 4 រំលត់ការគំរាមគំហែង




ទុកដាក់ភួយពន្លត់អគ្គីភ័យនិងឧបករណ៍ពន្លត់អគ្គីភ័យនៅក្នុងចង្ក្រានបាយ។

ភ្លើងឆេះតូចតាចនៅក្នុងគេហដ្ឋាននឹងអាចរាលដាលធំមិនអាចត្រួតពិនិត្យបានយ៉ាងឆាប់រហ័ស ដូចនេះហើយ គ្រប់គេហដ្ឋានទាំងអស់គួរតែមានឧបករណ៍ពន្លត់អគ្គិភ័យជាមូលដ្ឋានដែលអាចងាយស្រួលនឹងយកបាន។

- ត្រូវប្រាកដថាគេហដ្ឋានរបស់លោកអ្នកមានឧបករណ៍ពន្លត់អគ្គិភ័យដែលបានថែរក្សាត្រឹមត្រូវ និងមានភួយពន្លត់អគ្គិភ័យ ហើយត្រូវចេះប្រើឧបករណ៍ទាំងនេះ។ ចូររកមើល ផលិតផលដែលសមស្របតាមស្តង់ដាអូស្ត្រាលី AS 2444 ។
- ការទុកដាក់ឧបករណ៍ទាំងនេះនៅក្នុងចង្ក្រានបាយគឺជាគំនិតល្អ ព្រោះថាអគ្គិភ័យ ភាគច្រើនចាប់ផ្តើមពីទីកន្លែងនេះ។
- ប្រសិនបើអគ្គិភ័យនោះមានទំហំតូចហើយនៅក្នុងគេហដ្ឋាន ហើយមានសុវត្ថិភាពសំរាប់ពន្លត់ ចូរពន្លត់ដោយប្រើភួយពន្លត់អគ្គិភ័យនិងឧបករណ៍ពន្លត់អគ្គិភ័យ។
- ឧបករណ៍ទាំងនេះគឺអាចរកទិញបាននៅតាមហាងលក់គ្រឿងដែក ឬផ្សារធំ ឬអាចបញ្ជារទិញបានពីមន្ទីរថែរក្សាឧបករណ៍ពន្លត់អគ្គិភ័យរបស់អង្គភាពពន្លត់អគ្គិភ័យ។

សំរាប់ព័ត៌មានបន្ថែម សូមបើកមើលវិបសាយ
**www.cfa.vic.gov.au/residents/home/equip.htm**

# 5 ការនៅរស់រានជីវិតពីអគ្គីភ័យក្នុងគេហដ្ឋាន

## តើលោកអ្នកដឹងថាត្រូវធ្វើអ្វីខ្លះទេនៅពេលអគ្គីភ័យឆេះគេហដ្ឋានរបស់លោកអ្នក?

**សមាជិកគ្រួសារទាំងអស់គួរតែរៀបចំផែនការភៀសខ្លួនចេញពីគេហដ្ឋាន ហើយសាកល្បងផែនការនោះ។**

ផែនការនេះត្រូវសំគាល់ច្រកចេញទាំងអស់នៅក្នុងគេហដ្ឋានរបស់លោកអ្នក ហើយត្រូវកំណត់ទីកន្លែងដែលសមាជិកគ្រួសារត្រូវជួបជុំគ្នានៅខណៈដែលពួកគេមានសុវត្ថិភាពនៅខាងក្រៅហើយ។

- មានផ្ទាំងក្រដាសនៅខាងក្រោយកូនសៀវភៅព័ត៌មាននេះសំរាប់ជួយលោកអ្នក។

អ្នកទាំងឡាយដែលមើលថែទាំកូនៗរបស់លោកអ្នក ឬអ្នកទាំងឡាយដែលស្នាក់នៅក្នុងគេហដ្ឋានរបស់លោកអ្នកគួរដឹងពីផែនការភៀសខ្លួនពេលមានអគ្គីភ័យ។ បង្ហាញច្រកចេញទាំងអស់ឲ្យពួកគេបានដឹង និងទីកន្លែងដាក់ទូរស័ព្ទនិងលេខទូរសព្ទពេលមានអាសន្ន។

**រក្សាលេខទូរស័ព្ទពេលមានអាសន្ននៅក្បែរទូរស័ព្ទ**

- ត្រូវធានាថាលេខទូរស័ព្ទពេលមានអាសន្នគឺមាននៅក្បែរទូរស័ព្ទទាំងអស់នៅក្នុងគេហដ្ឋានរបស់លោកអ្នក។
- ទូរស័ព្ទមកលេខ 000 សំរាប់ អគ្គីភ័យ ប៉ូលីស និងឡានពេទ្យ។
- ការបង្រៀនកូនក្មេងរបៀបទាក់ទងសេវាពេលមានអាសន្ន គឺមិនមែនជាការលឿនពេកនោះទេ។

**ធ្វើការហ្វឹកហាត់ពេលមានអគ្គីភ័យឲ្យបានទៀងទាត់ជាមួយសមាជិកគ្រួសារគ្រប់រូប និងសំគាល់ផ្លូវសំរាប់ចេញពីគេហដ្ឋានដោយសុវត្ថិភាពបំផុតសំរាប់គ្រប់បន្ទប់ទាំងអស់ រួមទាំងជាន់លើ។**

ឯកភាពពីទីកន្លែងសំរាប់ជួបជុំនៅខាងក្រៅ ហើយត្រូវអនុវត្តតាម។ កន្លែងប្រអប់សំបុត្រអាចជាកន្លែងសមរម្យមួយ។ ត្រូវធានាថាលេខគេហដ្ឋានរបស់លោកអ្នកគឺអាចមើលឃើញបានច្បាស់ ដូចនេះហើយសេវាពេលមានអាសន្នអាចរកលោកអ្នកឃើញបានឆាប់រហ័ស។

## ក្បួនសំរាប់រស់រានមានជីវិតពីអគ្គីភ័យ

**ប្រសិនបើសំលៀកបំពាក់របស់លោកអ្នកឆេះ សូមឈប់ ផ្តួលខ្លួនហើយរមៀលខ្លួនដើម្បីពន្លត់អណ្តាតភ្លើង។**

- ដើម្បីជួយនរណាម្នាក់ សូមបោះភួយក្រណាត់ឡែនពីលើខ្លួនពួកគេ។

**ប្រសិនបើមានផ្សែងនៅក្នុងគេហដ្ឋានរបស់លោកអ្នក ត្រូវអោនឲ្យទាប ហើយចេញ ចេញ ចេញ!**

- នៅក្នុងអគ្គីភ័យ កន្លែងដែលមានសុវត្ថិភាពជាងគេសំរាប់ដកដង្ហើម គឺនៅជិតកំរាលដែលនៅទីនោះ ខ្យល់ត្រជាក់ជាង ហើយបរិសុទ្ធជាង ដូចនេះត្រូវចាំថាត្រូវវារឲ្យបានទាបនៅក្នុងផ្សែង។

**ឆែកមើលកំដៅទ្វារមុននឹងបើក។**

- ប្រើខ្នងដៃរបស់លោកអ្នកឆែកមើលកំដៅ បន្ទាប់មកអោនឲ្យបានទាប ហើយវារចេញទៅរកកន្លែងសុវត្ថិភាព។ បិទទ្វារពីក្រោយលោកអ្នកបើអាចធ្វើទៅបាន។ ប្រសិនបើ ទ្វារក្តៅ ប្រើច្រកចេញមួយផ្សេងទៀត។

ឲ្យមនុស្សគ្រប់រូបចាកចេញពីគេហដ្ឋានឲ្យបានឆាប់តាមតែធ្វើទៅបាន។

ទូរស័ព្ទទៅអង្គភាពពន្លត់អគ្គីភ័យពីគេហដ្ឋានរបស់អ្នកជិតខាង ពីទូរស័ព្ទសាធារណៈ ឬទូរស័ព្ទដៃ ហើយរង់ចាំពួកគេមកដល់។

- ប្រាប់ពួកគេកន្លែងអគ្គីភ័យឆេះ ហើយប្រសិនបើនៅមានមនុស្សនៅខាងក្នុង។

កុំចូលទៅក្នុងគេហដ្ឋានវិញឲ្យសោះ ទោះបីដោយសារមូលហេតុអ្វីក៏ដោយ។



រៀបចំផែនការភៀសខ្លួនពីគេហដ្ឋាន



ឆែកមើលកំដៅតាមទ្វារ




ឯកភាពពីទីកន្លែងសំរាប់ជួបជុំគ្នានៅខាងក្រៅ

# 5 ការនៅរស់រានមានជីវិតពីអគ្គិភ័យក្នុងគេហដ្ឋាន



បង្ហូរទឹកលើកន្លែងរលាកដើម្បីឲ្យវាត្រជាក់



ត្រូវប្រាកដថាលោកអ្នកអាចបើកទ្វារបានពេលនៅខាងក្នុង

## រៀនរបៀបជួយសង្គ្រោះបឋមជាមូលដ្ឋាន

ប្រសិនបើមាននរណាម្នាក់រលាកភ្លើង:

1. **បញ្ឈប់ការរលាក**
   ដោះខោអាវចេញ លើកលែងតែខោអាវនោះវាស្អិតជាប់ស្បែក។
2. **ធ្វើឲ្យកន្លែងរលាកនោះត្រជាក់**
   ដាក់កន្លែងរលាកនោះចូលទៅក្នុងទឹក ឬបង្ហូរទឹកត្រជាក់លើកន្លែងរលាក សំរាប់រយៈពេលពី 15 ទៅ 20នាទី។ កុំប្រើខ្លាញ់ ប៊ឺរ ឬប្រេងលាបឲ្យសោះ។
3. **គ្របកន្លែងរលាក**
   គ្របកន្លែងរលាកជាមួយបន្ទះក្រណាត់ស្អាត ឬរុំហើយរក្សាកំដៅអ្នកជំងឺ។

ទៅជួបវេជ្ជបណ្ឌិតប្រសិនបើកន្លែងរលាកមានពងបែក ធំជាងកាក់ 20សេន ឬនៅលើមុខ ដៃ ជើង ឬប្រដាប់ភេទ។

**ទូរស័ព្ទមក 000 សំរាប់ឡានពេទ្យ។**

## កុំទុកឲ្យសោរសុវត្ថិភាពជាប់ទ្វារបង្អាក់ការភៀសខ្លួនរបស់លោកអ្នក

ជីវិតរបស់លោកអ្នកអាចអាស្រ័យលើថាតើលោកអ្នកអាចចេញពីគេហដ្ឋានរបស់លោកអ្នកបានលឿនប៉ុណ្ណានៅពេលមានអគ្គិភ័យ។

ផ្សែងរាលដាលយ៉ាងលឿន កាត់បន្ថយការមើលឃើញ និងបណ្តាលឲ្យបែកអារម្មណ៍។

- កុំចាក់សោរសុវត្ថិភាពជាប់ទ្វារនៅពេលនៅខាងក្នុងគេហដ្ឋាន។
- ប្រសិនបើលោកអ្នកត្រូវប្រើសោរសុវត្ថិភាពនៅខណៈដែលលោកអ្នកនៅគេហដ្ឋាន ទុកកូនសោរនៅក្នុងរន្ធសោរនោះ ឬតម្កើងកន្លែងព្យួរកូនសោរនៅក្បែរទ្វារ។

# 6 ផែនការភៀសខ្លួនពីអគ្គីភ័យក្នុងគេហដ្ឋាន




ភាគច្រើននៃអគ្គីភ័យដែលបណ្ដាលឲ្យស្លាប់ កើតមានឡើងនៅក្នុងគេហដ្ឋាន តែការស្រាវជ្រាវបង្ហាញថា ប្រជាជនរដ្ឋវិចតូរីយ៉ាជាច្រើនមិនមានផែនការពិស្ដារពីអ្វីដែលពួកគេនឹងធ្វើប្រសិនបើមានអគ្គីភ័យទេ។

គ្រប់គេហដ្ឋានទាំងអស់គួរតែមានផែនការភៀសខ្លួនពីអគ្គីភ័យគេហដ្ឋាន ហើយសាកល្បងឲ្យបានទៀងទាត់។

អគ្គីភ័យក្នុងគេហដ្ឋានអាចបណ្ដាលឲ្យខ្លួនលោកអ្នកប្រឈមមុខនឹងកំដៅសីតុណ្ហភាពលើសពី 600°C អង្សារ។ យ៉ាងណាមិញ មនុស្សភាគច្រើនស្លាប់ដោយសារតែស្រូបយកជាតិផ្សែង និងឧស្ម័នពុលជាយូរមុននឹងអណ្ដាតភ្លើងមកដល់ពួកគេ។

គ្រួសារដែលបានរៀបចំបានល្អ គឺទំនងជាអាចភៀសខ្លួនពីគេហដ្ឋានរបស់ពួកគេដោយសុវត្ថិភាពជាង នឹងដោយមិនជ្រួលច្របល់។

ប្រើក្រដាសក្រឡាដែលមានភ្ជាប់មកជាមួយដើម្បីបង្កើតផែនការភៀសខ្លួនពីអគ្គីភ័យគេហដ្ឋាន ហើយដាក់តាំងបង្ហាញឲ្យបានឃើញច្បាស់។ ទូរទឹកកកគឺជាកន្លែងល្អមួយ។

ប្រមូលសមាជិកគ្រួសារទាំងអស់ ហើយគូសផែនការភៀសខ្លួនពីអគ្គីភ័យក្នុងគេហដ្ឋាននៅលើក្រដាសក្រឡា គូសបញ្ជាក់ច្រកចេញទាំងអស់។

ឲ្យកូនក្មេងចូលរួមផង។ ឲ្យពួកគេជួយរកច្រកចេញពីរដែលលឿននិងមានសុវត្ថិភាពបំផុតពីបន្ទប់និមួយៗនៃគេហដ្ឋានរបស់លោកអ្នកដោយរួមទាំងជាន់លើផង។

ឯកភាពពីទីកន្លែងសំរាប់ជួបជុំគ្នានៅខាងក្រៅ ហើយអនុវត្តតាមការឯកភាពនេះ។ ទីកន្លែង ប្រអប់សំបុត្រអាចជាកន្លែងសមរម្យមួយ។

បន្ទាប់ពីលោកអ្នកបានរៀបចំផែនការរបស់លោកអ្នករួចហើយ ធ្វើការហ្វឹកហាត់ភៀសខ្លួនពីអគ្គីភ័យឲ្យបានទៀងទាត់ ហើយសង្កេតមើលថាតើសមាជិកគ្រួសារអាចចាកចេញពីគេហដ្ឋានបានលឿនរបៀបណា។ នេះគឺជាគំនិតល្អបើអាចធ្វើការសាកល្បងយ៉ាងហោចណាស់ឲ្យបានពីរដងក្នុងមួយឆ្នាំ - ហើយឲ្យបានកាន់តែញឹកញាប់ជាងនេះ ប្រសិនបើលោកអ្នកមានក្មេងតូចៗ។

## ចំណុចសំខាន់ៗសំរាប់សុវត្ថិភាពអគ្គីភ័យក្នុងគេហដ្ឋាន

- មិនត្រូវដើរចោលការដាំស្ល ម៉ាស៊ីនកំដៅ ឡកំដៅភ្លើងចំហរ ឬ ទៀន ទេ។
- កុំប្រើបន្ទះរន្ធដោតឌុយភ្លើងលើសចំណុះ។
- រក្សាឧបករណ៍ប្រើអគ្គីសនីឲ្យដំណើរការបានល្អ។
- ត្រូវប្រាកដថាកំរាលមុងបារីនិងកន្ទុយបារីត្រូវបានពន្លត់។ មិនត្រូវជក់បារីលើគ្រែដាច់ខាត។
- កុំហាលខោអាវនៅជិតម៉ាស៊ីនកំដៅពេក។
- សំអាតតំរងកំទេចកំទីនៅក្នុងម៉ាស៊ីនសម្ងួតខោអាវឲ្យបានទៀងទាត់ ហើយជានិច្ចជាកាល ទុកឲ្យម៉ាស៊ីនសម្ងួតបញ្ចប់វដ្តធ្វើឲ្យត្រជាក់សិន។
- ទុកឈើគូសនិងដែកកេះឲ្យឆ្ងាយពីដៃកូនក្មេង។
- តាមច្បាប់ គេហដ្ឋាននិមួយៗយ៉ាងហោចណាស់ត្រូវមានឧបករណ៍ប្រកាសអាសន្នផ្សែងដែលដំណើរការចំនួនមួយតម្លើងនៅតាមជាន់និមួយៗនៃគេហដ្ឋាន។ សំអាតនិងឆែកមើលឧបករណ៍ប្រកាសអាសន្នឲ្យបានទៀងទាត់ ហើយត្រូវប្រាកដថាឧបករណ៍នោះដំណើរការល្អ។
- ត្រូវមានឧបករណ៍ពន្លត់អគ្គីភ័យនិងភួយពន្លត់អគ្គីភ័យ ហើយត្រូវចេះរបៀបប្រើ។
- ត្រូវមានផែនការភៀសខ្លួនពីអគ្គីភ័យ ហើយត្រូវសាកល្បងផែនការនោះ។
- កុំចាក់សោរសុវត្ថិភាពទ្វារនៅពេលលោកអ្នកនៅក្នុងគេហដ្ឋាន។ ទុកកូនសោរ សុវត្ថិភាពទ្វារនោះនៅក្នុងរន្ធ ឬនៅក្បែរនោះ។

# ផែនការភៀសខ្លួនចេញពីគេហដ្ឋានរបស់លោកអ្នក

- គូរប្លង់គេហដ្ឋានរបស់លោកអ្នកនៅលើក្រដាសមានក្រឡា និងគូសសំគាល់ច្រកចេញទាំងអស់។
- កំណត់ច្រកសំរាប់ចេញចំនួនពីរសំរាប់បន្ទប់និមួយៗ។
- សំរេចទីកន្លែងសំរាប់ជួបជុំនៅខាងក្រៅដូចជានៅក្បែរប្រអប់សំបុត្រ។
- សាកល្បងផែនការភៀសខ្លួនចេញពីគេហដ្ឋានរបស់លោកអ្នកឲ្យបានទៀងទាត់ជាមួយសមាជិកគ្រួសារទាំងអស់របស់លោកអ្នក។
- ទុកផែនការនេះនៅកន្លែងងាយស្រួលនឹងឃើញដើម្បីរំលឹកសមាជិកគ្រប់រូបពីច្រកចេញដោយសុវត្ថិភាពនៅក្នុងករណីមានអគ្គីភ័យ។ បិទលើទូរទឹកកករបស់លោកអ្នក។



CHECK YOUR HOTSPOTS

### ឧបករណ៍ប្រកាសអាសន្នផ្សែង

ឧបករណ៍ប្រកាសអាសន្នផ្សែងដែលដំណើរការគឺជួយជីវិត។

សូមធ្វើតេស្តនិងសំអាតឧបករណ៍ប្រកាសអាសន្នផ្សែងឲ្យបានទៀងទាត់។

### ម៉ាស៊ីនកំដៅ

ឆែកមើលម៉ាស៊ីនកំដៅរបស់លោកអ្នក មុនពេលលោកអ្នកប្រើលើកដំបូងរៀងរាល់រដូវត្រជាក់។

ដាក់សំលៀកបំពាក់ វាំងនន និងប្រដាប់ប្រដាក្មេងលេង យ៉ាងហោចណាស់ចំងាយមួយម៉ែត្រ ពីម៉ាស៊ីនកំដៅរបស់លោកអ្នក។

### ទៀន

ដាក់ឲ្យឆ្ងាយពីវាំងនន។

ជានិច្ចជាកាល ត្រូវប្រើលើផ្ទៃដែលមិនឆេះ។



### បន្ទប់គេង

ប្រើឧបករណ៍តែមួយគត់សំរាប់រន្ធអគ្គីសនីនិមួយៗនៅលើបន្ទះរន្ធអគ្គីសនី។

### ភ្លួយអគ្គីសនី

បើកមិនឲ្យលើសពី 30នាទី មុននឹងចូលសំរាន្ត។

បិទមុននឹងសំរាន្ត។

### ផ្ទះបាយ

ដឹងរបៀបប្រើភួយពន្លត់អគ្គីភ័យ និងឧបករណ៍ពន្លត់អគ្គីភ័យ។

មិនត្រូវដើរចោលអាហារដែលកំពុងតែចំអិននោះទេ។

### ឡភ្លើងកំដៅចំហរ

ជានិច្ចជាកាលត្រូវដាក់របាំងពីមុខឡភ្លើងកំដៅចំហរ។

ពន្លត់ភ្លើងមុននឹងចូលសំរាន្ត ឬមុននឹង ចេញទៅក្រៅ។

### ទ្វារមុខ

កូនសោរសុវត្ថិភាពទ្វារគួរទុកនៅជាប់មេសោរទ្វារនៅពេលលោកអ្នកនៅក្នុងគេហដ្ឋាន។

បង្កើតនិងសាកល្បងផែនការភៀសខ្លួនចេញពីគេហដ្ឋានរបស់លោកអ្នក - ត្រូវមានច្រកចេញចំនួនពីរពីបន្ទប់និមួយៗ។

### បន្ទប់ទទួលភ្ញៀវ

កុំប្រើរន្ធអគ្គីសនីលើសចំណុះ។

ប្តូរខ្សែភ្លើងខូចចេញ។

### បន្ទប់បោកគក់ខោអាវ

សំអាតតំរងកំទេចកំទីក្នុងម៉ាស៊ីនសម្ងួតខោអាវបន្ទាប់ពីការប្រើម្តងៗ។

ទុកឲ្យម៉ាស៊ីនសម្ងួតនោះបញ្ចប់វដ្តរបស់វាបានសព្វគ្រប់ - ព្រោះការទុកឲ្យម៉ាស៊ីនត្រជាក់ជាការសំខាន់។

www.checkyourhotspots.com

## សំរាប់អគ្គីភ័យ ប៉ូលីស ឬឡានពេទ្យ សូមទូរស័ព្ទលេខ 000

CFA®

សំរាប់ព័ត៌មានបន្ថែម សូមបើកមើលគេហទំព័រ **www.cfa.vic.gov.au** ឬទូរស័ព្ទមក សុវត្ថិភាពសហគមន៍ អង្គភាពពន្លត់អគ្គីភ័យ លេខ (03) 9262 8444

ការប្រកាសមិនទទួលខុសត្រូវ

*អង្គភាពពន្លត់អគ្គីភ័យផ្តល់ជូននូវព័ត៌មាននេះនិងសំភារៈសំរាប់ផែនការភៀសខ្លួនដែលមានជូន ដោយអាស្រ័យលើការយល់ដឹងថាលោកអ្នកមានការយកចិត្តទុកដាក់សមហេតុសមផលនៅពេលប្រើប្រាស់នូវព័ត៌មាននិងសំភារៈទាំងនេះ។ ប្រសិនបើលោកអ្នកមិនដឹងច្បាស់ពីការប្រើប្រាស់ព័ត៌មានទាំងនេះសំរាប់កាលៈទេសៈជាក់លាក់របស់លោកអ្នកលោកអ្នកគួរតែ ស្វែងរកឱវាទវិជ្ជាជីវៈបន្ថែមទៀត។*

អង្គភាពពន្លត់អគ្គីភ័យមិនទទួលខុសត្រូវលើរបៀបដែលលោកអ្នកប្រើប្រាស់ បកស្រាយ ឬពឹងពាក់លើព័ត៌មានដែលមានជូននៅក្នុងបណ្ណព័ត៌មាននេះទេ។ អង្គភាពពន្លត់អគ្គីភ័យមិនទទួលយកនូវការទទួលខុសត្រូវលើការបាត់បង់ ឬខូចខាតដែលជាលទ្ធផលនៃការប្រើប្រាស់របស់លោកអ្នកនៃព័ត៌មានទាំងនេះ ទោះបីជាដោយសារតែភាពមិនត្រឹមត្រូវដោយអចេតនា ដោយកំហុស ឬការលុបចោល ឬដោយសារមូលហេតុណាមួយផ្សេងទៀត។

រចនាបថដោយ Mono Design www.monodesign.com.au រូបថតដោយ មាទីន អែនឌើសុន អង្គភាពពន្លត់អគ្គីភ័យ។